ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៥ ចុះថ្ងៃទី ២៨
ខែ មករា ឆ្នាំ ២០០៤
សាលក្រម
លេខ ៦៦ "គ" ចុះថ្ងៃទី ២៥
ខែ មិថុនា ឆ្នាំ ២០០៤

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តកំពង់ធំ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការខេត្តកំពង់ធំ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ ៈ

**<u>ចៅក្រមជំនុំជំរះ</u>**

លោកស្រី [redacted]

**<u>តំណាងអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted]

សាលក្រមនេះបានចូលស្ថាពរកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥
ហើយដោយគ្មានគូក្តីណាចូលមកប្តឹងតាមកំណត់ច្បាប់ ។
កំពង់ធំ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥
ចៅក្រមជំនុំជំរះ
[redacted]

**<u>ដើម្បីជំនុំជំរះ</u>**

១-ឈ្មោះ **ញ ស** ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ កើត និង រស់នៅសព្វថ្ងៃ ភូមិឈូកគ្រួស ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ មុខរបររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ **ខ ស** មានកូន ០៤នាក់ ឪពុកឈ្មោះ **ញ ម** (ស) ម្តាយឈ្មោះ **ន យ** (រ) ទោសពីមុន *គ្មាន* ។

២-ឈ្មោះ **ជ ញ** ភេទស្រី អាយុ ៥០ឆ្នាំ ជាតិខ្មែរ កើត និង រស់នៅភូមិឈូកគ្រួស ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មុខរបររកស៊ីធ្វើស្រែ ប្តីឈ្មោះ **ស ស** (ស) មានកូន ០១នាក់ ឪពុកឈ្មោះ **រ ជ** (ស) ម្តាយឈ្មោះ **ស ឧ** (ស) ទោសពីមុន *គ្មាន* ។

អ្នកទាំងពីរខាងលើចោទពីបទ **បរិហាកេរ្តិ៍គ្នាទៅវិញទៅមក** ប្រព្រឹត្តនៅ ភូមិឈូកគ្រួស ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ តាមបញ្ញត្តិ មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ **ជ ញ** ភេទស្រី អាយុ ៤៩ឆ្នាំ នៅភូមិឈូកគ្រួស ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ប្តឹងថា ថ្ងៃ ពុធ ទី ១២ ខែ មីនា ឆ្នាំ ២០០៣ ឈ្មោះ **ញ ស** បានមកផ្ទះខ្ញុំជេរបញ្ចោរ និង បរិហាកេរ្តិ៍ខ្ញុំនៅលើផ្ទះ មើលងាយមើលថោកក្រុមគ្រួសារខ្ញុំ សុំទាមទារជំងឺចិត្ត ១.៥០០.០០០រ០០ ។

-ដីកាសន្និដ្ឋានចោទប្រកាន់លេខ ៧៤ អក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។



Scanned with CamScanner

## ២.រឿងហេតុមានដូចតទៅ

នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣ ម៉ោង ១៦:៣០នាទី ឈ្មោះ ញ សរ បានទៅផ្ទះ ៩ ញ ទៅសួរឈ្មោះ ណ ពីរឿងវ៉ាវវ៉ាឈ្មោះ ៩ ញ បានថា មិនបានឃ្វាលក្តិតវ៉ាទេ ពូជវ៉ាសំផឹងពីម៉ែវហូតដល់កូន ក៏ឈ្មោះ ញ សរ បានតបថា ពូជវ៉ាសំផឹងពីម៉ែដល់កូន បានជាវ៉ាយកទៅធ្វើសំផឹង មានការប្រកែកគ្នាទៅវិញទៅមក ឈ្មោះ ញ សរ ក៏ត្រឡប់មកផ្ទះវិញ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ញ សរ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ វេលាម៉ោង ៣រសៀល ខ្ញុំទៅផ្ទះ ៩ ញ ។ បានទៅដល់ផ្ទះគាត់ឃើញ ៩ ញ និង ឈ្មោះ ៣ ស បានសួរទៅគាត់ពីរឿងកូនឈ្មោះ ណ ពេលនោះឈ្មោះ ៣ ស បានថា គ្មាននរណាការពារក្តិតវ៉ាទេ វ៉ាចេញពីផ្ទះខ្ញុំហើយ ។ ខ្ញុំបានថា យកកូនអញមិនទទួលខុសត្រូវទេ ។ ឈ្មោះ ៩ ញ ឆ្លើយថា ពូជវ៉ាសំផឹងទៅរកធ្វើតែសំផឹង ។ ខ្ញុំបានថា ពូជវ៉ាសំផឹង សំផឹងទាំងម៉ែ ខ្ញុំចុះចេញពីផ្ទះ ៩ ញ វ៉ាជេរខ្ញុំ អាថ្លើមខ្មៅ ។ ខ្ញុំមិនបានបរិហាកេរ្តិ៍ ៩ ញ ទេ ។ សូមឱ្យតុលាការជួយរកយុត្តិធម៌ឱ្យផង ទាមទារសំណងជំងឺចិត្ត ៣.០០០ដុល្លាអាមេរិក ។

ដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទឈ្មោះ ៩ ញ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០០ វេលាម៉ោង ៤:៣០នាទីល្ងាច ឈ្មោះ ញ សរ ឡើងលើផ្ទះចោទសួរកូនធម៌ឈ្មោះ ស ថា ឯងម៉េចក៏ដើរនិយាយថា កូនអញមានប្រុសអាបោក មេបោក ឆាប់រកប្រុសឱ្យឃើញ មានការជេរបញ្ចោរពាក្យអាសអាភាស និង ឡូឡាខ្លាំងពេក ខ្ញុំបានបណ្តេញវ៉ាឱ្យចុះចេញពីផ្ទះភ្លាម វ៉ាចុះចេញដើរបណ្តើរជេរបណ្តើរហូតដល់ផ្ទះ ហើយថា ចង់ប្តឹងដល់ណាក៏ប្តឹងទៅ ។ ស្អែកឡើងកូនស្រីឈ្មោះ ៩ ស បានសួរទៅឈ្មោះ ញ សរ ថា ម៉េចបានជេរបញ្ចោរអញគាត់ថា អញមិនជេរហែងទេ អញជេរតែម៉ែហែងមី ញ ពេលនោះ ខ្ញុំទៅដោះស្រាយនៅមេភូមិ តែគាត់ប្រាប់ឱ្យទៅដោះស្រាយលោកមេឃុំ និង ទៅអភិបាលស្រុកទៀត គាត់ទទួលស្គាល់ព្រមបង់ប្រាក់ឱ្យខ្ញុំ ៥០០.០០០រ០០ តែខ្ញុំទាមទារឱ្យបង់ ១.០០០.០០០រ០០ ទៅ ១០.០០០.០០០រ០០ ដោយគាត់ថា ខ្ញុំនាំកូនគាត់ទៅលក់ តាមពិតខ្ញុំមិនបានយកទៅលក់ទេ ។ សុំផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារសំណង និង ជំងឺចិត្តជាប្រាក់ ៣.០០០ដុល្លា ។

សាក្សីជនល្មើស ៩ ញ ឈ្មោះ ៩ ស បានឆ្លើយបញ្ជាក់ថា ម្តាយខ្ញុំ ៩ ញ បានប្រាប់ខ្ញុំថា កូនឯងមើលអា រ វ៉ាជេរអញ ហើយវ៉ាជេរកូនឯងទៀត ខ្ញុំសួរទៅ ញ រ ម៉េចបានជា រ ជេរខ្ញុំ វ៉ាបានឆ្លើយថា អញមិនបានជេរហែងទេ ជេរតែម៉ែហែង មេ ញ ខ្ញុំឈប់សួរ ឈប់និយាយចូលផ្ទះ ដោយខ្លាចមានរឿង ។

សាក្សីបំភ្លឺឈ្មោះ ស ស បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃ ខែមិនចាំ ថ្ងៃរសៀលខ្ញុំទៅធ្វើគ្រែងផ្ទះ ក៏ឈ្មោះ ញ សរ ធ្វើជាមួយបានមួយសន្ទុះ ឈ្មោះ ញ សរ ថា ទៅផ្ទះ ៩ ញ ដើម្បីទៅសួរនាំកូនគាត់ ទៅបានមួយសន្ទុះស្រាប់តែឮប្រកែកគ្នារវាងឈ្មោះ ៩ ញ និង ឈ្មោះ ញ សរ ខ្ញុំឮជេរគ្នាទៅវិញទៅមក ពាក្យជៀលត្និះសុទ្ធតែមីសំផឹង ទាំងម៉ែទាំងកូន អ្នកទាំងពីរប្រើពាក្យដូចគ្នាទៅវិញទៅមក ប្រកែកគ្នាដដែលៗ ក៏ឃើញឈ្មោះ ញ សរ ត្រឡប់មកផ្ទះវិញ ។

សាក្សីបំភ្លឺឈ្មោះ ៩ ស បានឆ្លើយបញ្ជាក់ថា ប្តីខ្ញុំឈ្មោះ ញ សរ បានទៅផ្ទះ ៩ ញ ដើម្បីសួរនាំអំពីរឿងកូន ។ មួយសន្ទុះក្រោយមក ឮប្រកែកគ្នាឡូឡាខ្លាំងពេក ខ្ញុំក៏ដើរទៅស្តាប់មុខផ្ទះ ៩ ញ ឃើញឈ្មោះ ៣ ស. ៩ ញ និង ញ សរ មានការប្រកែកគ្នា ដោយសារប្តីខ្ញុំទៅសួរឈ្មោះ ៣ ស ថា ឯងលួចយកកូនអញ មិនទទួលខុសត្រូវ



Scanned with CamScanner

ហេតុអីឯងថា អញមិនតាមឃ្នាលក្តិតអាណា ក៏ឈ្មោះ ជ ញ ឆ្លើយ ពូជវាសំផឹងបានជាវាដើរធ្វើសំផឹង ប្តីខ្ញុំបានត ទៅវិញថា ពូជវាក៏ធ្វើសំផឹងដែរ បានជាយកទៅនៅឱ្យធ្វើសំផឹង ប្តីខ្ញុំក៏ចុះចេញពីផ្ទះឈ្មោះ ជ ញ ត្រឡប់មកផ្ទះវិញ ។

សាក្សីបំភ្លឺឈ្មោះ ព ស បានឆ្លើយបញ្ជាក់ថា ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ វេលាម៉ោង ៤:៣០នាទី ល្ងាច ខ្ញុំនៅលើផ្ទះម្តាយធម៌ឈ្មោះ ជ ញ ស្រាប់តែឃើញឈ្មោះ ញ សរ បានឡើងលើដោះអាវស្បែកខោខ្លីបានជេរ ទៅលើម្តាយខ្ញុំ មីចោរសំផឹង យកកូនអញទៅលក់ ដើរនិយាយថា កូនអញមានប្រុស ជេរពាក្យអាសអាភាស ម្តាយ ខ្ញុំគាត់បានដេញឱ្យចេញពីផ្ទះ ។ ខ្ញុំមិនហ៊ានតទេ ឃើញ ញ សរ មានបំណងរកវាយផង ។

សាក្សីបំភ្លឺឈ្មោះ ជ ឈ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ វេលាម៉ោង ៤ល្ងាច បានឮឈ្មោះ ស ធ្វើនគរបាលឃុំឈូក បានប្រាប់ខ្ញុំថា ឃើញ ញ សរ ទៅជេរប្អូនស្រីឈ្មោះ ជ ញ ខ្ញុំបានទៅសួរប្អូន ភ្លាម ទៅដល់ឈ្មោះ ញ សរ ចេញផុត ខ្ញុំក៏សួរទៅប្អូន ជ ញ វាប្រាប់ថា ៖ វាមកជេរវាដល់ផ្ទះចោទថា យកកូនវា ទៅលក់ ខ្ញុំមិនបានឮផ្ទាល់ទេ តែបានឃើញ ញ សរ ដើរចេញពីផ្ទះ ជ ញ ។

សាក្សីបំភ្លឺឈ្មោះ ឡ យ បានឆ្លើយបញ្ជាក់ថា ថ្ងៃ ខែ មិនចាំ ឆ្នាំ ២០០៣ ខ្ញុំមិនដឹងថា ឈ្មោះ ជ ញ និង ញ សរ ឈ្លោះគ្នាទេ ០២នាក់នេះ ជាបងប្អូននឹងគ្នា ។ ក្រោយពីរថ្ងៃបានដឹងឈ្លោះគ្នា ដោយអ្នកទាំងពីរទៅរកខ្ញុំជា មេភូមិដោះស្រាយ ដោយ ជ ញ បានថា ឈ្មោះ ញ សរ ជេរបញ្ចោរយ៉ាងអាសអាភាសថា មកពីកូនធម៌ឈ្មោះ ស បាននាំកូនគេទៅជេរ នៅភ្នំពេញនោះថា យកកូនគេទៅលក់បណ្តាលឱ្យជេរគ្នាទៅវិញទៅមក ខ្ញុំបានប្រាប់ថា មិន អាចដោះស្រាយបានទៅឃុំទៀតទៅ រួចគេទៅដោះស្រាយនៅឃុំទៀត ។ ខ្ញុំមិនដឹងប្រវត្តិរូបឈ្មោះ ស កូនធម៌ ឈ្មោះ ជ ញ ទេ ។ ឈ្មោះ ណា ពិតជាទៅដេររោងចក្រសព្វថ្ងៃមកវិញហើយ ។

សាក្សីឈ្មោះ ន ឡអ បានឆ្លើយបញ្ជាក់ថា ខ្ញុំជាមេឃុំឈូក ខ្ញុំបានដោះស្រាយឈ្មោះ ញ សរ និង ឈ្មោះ ជ ញ ដែលអ្នកទាំងពីរជាបងប្អូននឹងគ្នា ។ ឈ្មោះ ជ ញ ថា ឈ្មោះ ញ សរ ទៅជេរបញ្ចោរយ៉ាងអាសអាភាស ដែលទ្រាំមិនបានក៏ជេរតបទៅវិញ ។ ខ្ញុំបានដោះស្រាយឱ្យនោះ ខ្ញុំស្តាប់ទៅ កូនធម៌ ជ ញ បាននាំកូនគេទៅជេរ នៅ កំពង់សោម ដោយមិនបានប្រាប់ឪពុកគេទេ ។ នាងនោះទៅជេរមានសង្សារ ទើបឪពុកម្តាយនាង ណា ថា គេយក កូនទៅលក់ ។ ខ្ញុំសំរុះសំរួលអ្នកទាំងពីរឈប់ទាស់គ្នាទៅ ។ រឿងនេះគេឱ្យខ្ញុំបញ្ជូនរឿងទៅទៀត ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនល្មើសឈ្មោះ ញ សរ និង ឈ្មោះ ជ ញ មានការបរិហា កេរ្តិ៍គ្នាទៅវិញទៅមកថា ពូជសំផឹងទៅវិញទៅមក ។ អយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តី ទៅតាមច្បាប់ ។

-បានស្តាប់ចម្លើយជនជាប់ចោទ

-បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-បានស្តាប់ចម្លើយសាក្សី

-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

បានពិនិត្យសំណុំរឿងចប់សព្វគ្រប់

**<u>តុលាការខេត្តកំពង់ធំ</u>**

**<u>យល់ឃើញថា</u>**

-កាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣ ឈ្មោះ ញ សរ និង ឈ្មោះ ជ ញ មានការបរិហាកេរ្តិ៍គ្នាទៅ វិញទៅមក ដោយ ញ សរ ចោទ ជ ញ យកកូនស្រីខ្លួនឈ្មោះ ណា យកទៅលក់ ។



Scanned with CamScanner

-ញ សរ ថា ឈ្មោះ ៩ ញ ជេរគាត់ថា សំដីងអស់មួយពូជ ក៏ ៩ ញ ថា សំដីងទាំងម្តាយទាំងកូនទៅវិញ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា រក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តីទៅតាមច្បាប់ ។

-ញ សរ ទាមទារជំងឺចិត្ត ៣.០០០ដុល្លាអាមេរិក តុលាការពិចារណា ។

-៩ ញ ជាដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនជាប់ចោទសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជំងឺចិត្ត ៣.០០០ដុល្លា តុលាការពិចារណា ។

-ញ សរ និង ឈ្មោះ ៩ ញ ល្មើសនឹងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## <u>ហេតុដូច្នេះតុលាការខេត្តកំពង់ធំ</u>
## <u>វិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោស ឈ្មោះ ញ សរ ភេទប្រុស អាយុ ៤១ឆ្នាំ ឈ្មោះ ៩ ញ ភេទស្រី អាយុ ៥០ឆ្នាំ ម្នាក់១ ជាប់ពន្ធនាគារ ០៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ ។ ទោសខាងលើនេះ គិតតាំងពីថ្ងៃប្រកាសសាលក្រមនេះ មានអានុភាពតទៅ ពីបទ **បរិហាកេរ្តិ៍ឆ្លាទៅវិញទៅមក** ប្រព្រឹត្តនៅភូមិឈូកគ្រួស ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣ តាមបញ្ញត្តិមាត្រា ៦៣, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-សំរេចពិន័យលើឈ្មោះ ញ សរ និង ឈ្មោះ ៩ ញ ម្នាក់១ ជាប្រាក់ ០៣ម៉ឺនរៀល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ។

៣-ឱ្យឈ្មោះ ញ សរ ជូសជុលជំងឺចិត្តជាប្រាក់ ១០ម៉ឺនរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ជាជនជាប់ចោទ ឈ្មោះ ៩ ញ បណ្តឹងលើសពីនេះត្រូវលើកចោល ។ បើឈ្មោះ ញ សរ មិនមានប្រាក់បង់ទេ បង្ខំរូបកាយដាក់គុកទារប្រាក់ធនទណ្ឌ ។

សំរេចឱ្យឈ្មោះ ៩ ញ ជូសជុលជំងឺចិត្តជាប្រាក់ ១៥ម៉ឺនរៀល ឱ្យទៅឈ្មោះ ញ សរ ជាដើមបណ្តឹង និង ជាជនជាប់ចោទ លើសពីនេះត្រូវលើកចោល បើឈ្មោះ ៩ ញ មិនមានប្រាក់បង់ទេ បង្ខំរូបកាយ ដាក់គុកទារប្រាក់ធនទណ្ឌ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខានិងត្រា :** [redacted]

**បានឃើញ**

**ចៅក្រមជំនុំជំរះតុលាការខេត្តកំពង់ធំ**

[redacted]



Scanned with CamScanner